# ដំឡូងឈើ





គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445-CAM ( SF )
នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
លេខ : ២ ឆ្នាំ ២០០៣

## ១_សារៈប្រយោជន៍របស់ដំឡូងឈើ :

ដំឡូងឈើជាដំណាំអាហារមួយប្រភេទ ដែលអាចហូបជំនួសបាយបាន នៅពេលអ្នកខ្វះអង្ករ ។ ក្រៅពីធ្វើជាអាហាររបស់ មនុស្ស គេអាចយកទៅធ្វើជាចំណីសត្វបានយ៉ាងល្អ ស្លឹកដំឡូងឈើ គេអាចយកទៅធ្វើជាបន្លែស្រស់ អន្លក់ ។ល ។ គេអាចយកម្សៅដំឡូងឈើធ្វើជា នំបុ័ងជំនួសស្រូវសាឡីបាន ជាងនេះទៅទៀត ដំឡូងឈើក៏ជាវត្ថុធាតុដើមរបស់រោងចក្រសំរាប់ផលិតក្រដាសធ្វើ ជ័រ ។

## ២_ប្រភេទពូជ :

ដំឡូងឈើដែលគេនិយមដាំនៅក្នុងប្រទេសកម្ពុជាយើងមានពូជនាំមកពីបរទេស និង ពូជនៅក្នុងស្រុក ពូជទាំងនោះមាន ពូជស្រាល និងពូជធ្ងន់ ។ បើគេបែងចែកពូជទៅតាមលក្ខណៈ មើមរបស់ដំឡូងក៏មានពីរប្រភេទដែរគឺ :

### *ក-ពូជដែលមនុស្សហូបមើម :*

ពូជនេះ មើមរបស់វាមានសាច់មើមម៉ដ្ឋរសជាតិផ្អែមច្រើនជាងល្វីងហើយវាជាពូជដែលធន់ទ្រាំទៅនឹងការរាំងស្ងួត និង មានរយៈពេលលូតលាស់ខ្លី គឺ ៨_១២ ខែ ។

## ២-ប្រភេទពូជសំរាប់ធ្វើម្សៅនិងចំណីសត្វ :

ពូជនេះ មើមរបស់វាមានសាច់មើមគ្រើមមិនស្វិតមានរសជាតិល្វីងទាំងអស់ ។ ប្រភេទពូជនេះមានរយៈពេលលូតលាស់វែង ។

# ៣_បច្ចេកទេសដាំដុះ :

## ៣.១-ការធ្វើដី :

- អ្នកត្រូវកាប់ឬភ្ជួរដីអោយបានជំរៅប្រហែលពី ២០_៣០ស.ម ភ្ជួរឱ្យបានពីរទៅបីដងដើម្បីឱ្យដីផុសល្អ បន្ទាប់មកអ្នកត្រូវរើសយកស្មៅចេញអោយបានស្អាត ។

- អ្នកត្រូវហាលដីអោយបានស្ងួតល្អ ។



*ការរៀបចំហាលដី*

### ៣.២-ការរើសពូជ :

- អ្នកត្រូវរើសយកដើមដំឡូងណា ដែលធំមានលក្ខណៈដុះលូតលាស់ល្អ និង មានអាយុកាលយ៉ាងតិចមួយឆ្នាំ ។

- អ្នកត្រូវកាត់ជាកង់ៗ *ប្រវែងពី ១៥-២០ស.ម* ។

### ៣.៣-រដូវកាលដាំដុះ :

អ្នកគួរដាំដំឡូង នៅពេលដែលដីមានសំណើមគ្រប់គ្រាន់ ហើយសំណើមនៅក្នុងដីនោះអាចធានានូវការលូតលាស់របស់ដំឡូង ក្នុងរយៈពេល៤-៥ខែ ដូច្នេះពេលវេលាដ៏សមស្រប និងល្អបំផុតនោះ គឺក្នុងអំឡុងខែវិច្ឆិកា និងធ្នូ ជាពិសេសបន្ទាប់ពីទឹកទន្លេស្រកចុះ ។

### ៣.៤-វិធីសាស្ត្រដាំដុះ :

*ការដាំដំឡូងឈើជាទូទៅគេដាំតាមបីរបៀបៈ*

#### ក-ការដាំបញ្ឈរ :

ការដាំតាមវិធីនេះ អ្នកត្រូវដាក់កំណាត់ដំឡូងឈើរាងបញ្ឈរដែលមានមុំពី ២០-៤៥ ដឺក្រេ ដោយប្រៀបធៀបទៅនឹងដី ។ ជាទូទៅការដាំអ្នកត្រូវកប់ដើមដំឡូងឈើផ្នែកខាងក្រោមនៃដងដើម ទៅក្នុងដីអោយជ្រៅ ជួនកាលអ្នកអាចកប់ជិតតែម្ដង ឬ ទុកផ្នែក ខាងចុងដើមលេចផុតពីដីបន្តិច ។



*ការបង្ហាញពីរបៀបដាំបញ្ឈៀង*

## ខ-ការដាំផ្ដេក

ការដាំរបៀបនេះអ្នកត្រូវដាក់ដើមដំឡូងផ្ដេកនៅក្នុងជួរតែម្ដង ឬ បាតរងតែម្ដងរួចអ្នកត្រូវកប់ដីពីលើដែលមានកំរាស់ *ពី ៥-១០ ស.ម។*



*ការបង្ហាញពីរបៀបដាំផ្ដេក*

## គ-ការដាំបញ្ឈរ

ការដាំរបៀបនេះ អ្នកត្រូវដាំដើមដំឡូងបញ្ឈរក្នុងដីតែម្តង គឺអ្នកត្រូវកប់ផ្នែកចាស់នៃដើមទៅក្នុងដី ហើយទុកផ្នែកខាងចុងនៅផុតពីដី ។

ចំពោះវិធីសាស្ត្រទាំងបីខាងលើនេះ ជាទូទៅគេច្រើននិយមដាំតាមរបៀបបញ្ឈៀង ឬ ផ្តេកហើយ ពីព្រោះវាផ្តល់ទិន្នផលខ្ពស់ ។



ការបង្ហាញពីរបៀបដាំបញ្ឈរ

## ឃ-ចន្លោះឃ្លាត

| ចន្លោះពីជួរ១ទៅជួរ១ | ចន្លោះពីដើម១ទៅដើម១ | ចំនួនដើម |
|---|---|---|
| ៩០ ស.ម | ៦០ ស.ម | ១៨ ០០០ ដើម/ហិកតា |
| ៩០ ស.ម | ៩០ ស.ម | ១២ ០០០ ដើម/ហិកតា |
| ៩០ ស.ម | ១២០ ស.ម | ៩ ០០០ ដើម/ហិកតា |

ប៉ុន្តែជាទូទៅគេច្រើនដាំដំឡូងឈើ ក្នុងចន្លោះពីគុម្ពមួយទៅ គុម្ពមួយប្រវែងមួយម៉ែត្រ ហើយចន្លោះពីជួរមួយទៅជួរមួយគឺប្រវែង មួយម៉ែត្រដែរ ។



ចន្លោះពីគុម្ពមួយទៅគុម្ពមួយ ១ ម៉ែត្រ

## ខ- ជម្រៅដែលត្រូវដាំ

អ្នកត្រូវប្រើចបជីកឬចបកាប់ ដើម្បីកាប់ដីអោយបានជម្រៅពី ៧-១០ស.ម ហើយកប់កំណាត់ដំឡូងទៅតាមស្នាមចបនោះ ។

## ៣.៥- ការប្រើជី :

- ប្រភេទជីដែលអ្នកត្រូវប្រើនោះ គឺ ជីប្រភេទ ៨-១៦-១៩ ដាក់ក្នុងចំនួនពី ៦០-១០០ គីឡូក្រាមក្នុងផ្ទៃដី ១៦០០ សង់ទីម៉ែត្រ ការ៉េ ។

លើកទី១នៅពេលដែលដំឡូងមានអាយុបានមួយខែបន្ទាប់ពីដាំ ។ ដាក់លើកទីពីរ នៅពេលដែលដំឡូងមានអាយុបីខែក្រោយពីដាំ ហើយត្រូវដាក់អោយបានឆ្ងាយពីគល់ដំឡូងបន្តិច គឺប្រហែលពី *២៥-៣០ស.ម* ហើយលុបដី ។

## ៣.៦-ការថែទាំ :

- ក្រោយពីដាំដំឡូងបានពី ៥ - ៧ ថ្ងៃ ត្រូវពិនិត្យមើលការដុះពន្លករបស់ដំឡូង អ្នកត្រូវដាំជួសឡើងវិញ ជាបន្ទាន់ចំពោះកន្លែងណាដែលមិនដុះ ។

- បន្ទាប់ពីដំឡូងមានអាយុ ៣០ ថ្ងៃ ត្រូវជ្រួយដី បោចស្មៅ អោយបានស្អាតល្អដើម្បីឱ្យដីផុសត្រសុសល្អ ។



*ការសំអាតស្មៅ*

- គួរសំអាតស្មៅអោយបានស្អាតនៅចន្លោះរងដំឡូង ដើម្បីអោយដំឡូងដុះលូតលាស់ល្អ ហើយនៅពេលធ្វើស្មៅ និងជ្រួយដី ត្រូវប្រយ័ត្នប្រយែងកុំអោយប៉ះទង្គិចដល់ឫសរបស់ដំឡូង ជាពិសេសនៅពេលដែលដំឡូងកំពុងចុះមើម ។

## ៣.៧-ការប្រមូលផល

ការប្រមូលផល វាអាស្រ័យទៅតាមពូជរបស់ដំឡូងឈើ ចំពោះពូជស្រាលត្រូវប្រមូលផលនៅពេលដែលដំឡូងមានអាយុ ៩-១០ ខែ ចំពោះពូជធ្ងន់ត្រូវប្រមូលផល នៅពេលដែលដំឡូងមាន អាយុ១២-១៣ខែ ។ ការប្រមូលផលមានពីររបៀបគឺដោយដៃ និង ដោយពាក់កណ្តាលយន្តសាស្ត្រ ។

### ក-ការប្រមូលផលដោយដៃ

អ្នកត្រូវកាប់ដើមដំឡូងឈើចោលជាមុនសិន ដោយទុកដងដើមត្រឹមតែកំពស់ប្រមាណ *២០-៥០ស.ម* ការកាប់ដើមនោះ គឺងាយស្រួលក្នុងការដក ។ ពេលដកមើមអ្នកត្រូវរញ្ជួយ ឬ រង្គៀកដើមជាមុនសិន ទើបចាប់ផ្តើមដកបន្តិចម្តង១ ធ្វើយ៉ាងនេះគឺដើម្បីជៀសវាងការបាក់មើម រលាត់សំបកមើម ។ វិធីម្យ៉ាងទៀតត្រូវកាប់ដងដើម មួយផ្នែកចោល ហើយបន្ទាប់មកត្រូវទុកចោលពី ៧ - ១៤ ថ្ងៃ សិន ទើបចាប់ផ្តើមដក ។



*ការប្រមូលផលដោយដៃ*

### ខ - ការប្រមូលផលដោយពាក់កណ្ដាលយន្តសាស្ត្រ

ការងារនេះគឺជាការរួមផ្សំនិងឧបករណ៍ផ្សេងៗ ព្រមទាំងកំលាំងមនុស្ស ។

## ៤_ការទុកដាក់ :

មើមដំឡូងឈើជាទូទៅគឺមិនអាចធានាទុកបានយូរពេកទេ ពីព្រោះវាងាយរលួយខូចណាស់ គឺបណ្ដាលមកពីការរលួយខ្លួនវា និងបណ្ដាលមកពីមេរោគឬជំងឺផ្សេងៗ ។ គេអាចជៀសវាងចំពោះការរលួយរបស់ដំឡូងបានគឺតាមរយៈការរក្សាទុកមើមដំឡូងនោះ ដោយកប់ក្នុងដីឬកប់ក្នុងដីខ្សាច់សើម ឬដាក់មើមតំរៀបគ្នាក្នុងបាវសើមឬរុំដោយក្រដាសសើម ។ គេអាចរក្សាទុកមើមដំឡូងក្នុងរយៈពេល

យូរបាន ដោយទុកវានៅក្នុងទូ ឬ បន្ទប់ត្រជាក់ដែលមានសីតុណ្ហភាព ២៥ អង្សាសេ ព្រមទាំងស្ថិតក្នុងសំណើមអាកាសពី ៨៥-៩០ % ។

វិធីទុកម្យ៉ាងទៀតគឺគេចិតមើមដំឡូងនោះស្តើងៗ ហាលឱ្យស្ងួតរហូតដល់មានសំណើមក្នុងមើមដំឡូងនោះត្រឹម១០-១២% ប៉ុណ្ណោះ ។ គេអាចបន្ថយនូវការរលួយមើមបានមួយកំរិតតាមរយៈការកាប់ដើមចោលមុនពេលប្រមូលផលក្នុងរយៈពេលប្រមាណពី ៧-២១ ថ្ងៃ ។ ការទុកដាក់ដោយខ្ចប់ក្រដាសសើម គឺអាចបន្ថយភាពរលួយបានមួយកំរិត បើប្រៀបធៀបទៅនឹងការទុកដាក់ធម្មតា ។ បើក្នុងករណីដែលគេត្រូវនាំចេញមើមស្រស់ទៅលក់នៅកន្លែងឆ្ងាយ ឬ ប្រទេសឆ្ងាយ គឺ គេគួរតែប្រមូលផលនៅពេលដែលដំណាំមាន អាយុមិនលើសពី១០ខែ បន្ទាប់ពីដាំ ។

## ៥-ជំងឺនិងសត្វល្អិតចង្រៃ :

### *ក-ជំងឺរលួយឬស :*

ជំងឺនេះបង្កឡើងដោយពពួកផ្សិត ដោយវារាតត្បាតទៅលើប្រព័ន្ធឫសដែលស្ថិតនៅក្នុងដីនៃដំណាំនេះ ហើយធ្វើឱ្យរលួយភាគច្រើន នៅក្នុងរដូវភ្លៀង និងស្ថិតនៅក្នុងដីកណ្តុងជាំទឹក ព្រមទាំងមានជីធម្មជាតិច្រើន ។ មេរោគនៃជំងឺនេះច្រើនរាតត្បាតនៅលើ

ដីជាំទឹក ។ រោគសញ្ញានៃជំងឺនេះ វាធ្វើអោយដើមដងស្រពោន ងាប់បន្តិចម្តងៗ ថែមទាំងបញ្ចេញនូវទឹកម្យ៉ាងដែលមានក្លិនស្អុយ បន្ទាប់មកប្រព័ន្ធឫសរបស់ដំឡូងរលួយទាំងអស់តែម្តង ។

គេអាចជៀសវាង ជំងឺនេះបានតាមរយៈការជ្រើសរើសដី ដែលមានលក្ខណៈសមស្របល្អមិនជាំទឹក ឬ នៅកន្លែងដែលមានទឹក ជាប្រចាំ ។

### ខ-ជំងឺរលួយដើមដោយបាក់តេរី :

ដំឡូងដែលទទួលរងនូវជំងឺនេះ គេអាចសង្កេតឃើញនៅត្រួយ ឬ ពន្លកថ្មីរបស់វាក្រៀមស្ងួត ហើយមានភាពរលួយសើមនៅលើដង ដើម នៅលើផ្ទៃនៃដងដើមគេសង្កេតឃើញមានវន្ធតូចៗពាសពេញ ។ វន្ធទាំងនោះមានលក្ខណៈពិសេសមួយ ដែលងាយស្រួលក្នុងការកំណត់ ចំណាំ គឺគេឃើញមានជ័រស្ងួត ។ ពេលដែលគេកាត់ ដើមដែលមាន ជំងឺនេះមានលក្ខណៈក្រិនទាប និងប្រព័ន្ធឫសលូតលាស់ខ្សោយបំផុត។ គេអាចជៀសវាងបញ្ហានេះបានដោយគ្រាន់ តែជ្រើសរើសដើមណា ដែលមានសុខភាពល្អយកទៅធ្វើពូជឬជ្រើសរើសយកពូជធន់នឹង ជំងឺនេះ ។

## ៦-ផ្នែកអាហារូបត្ថម្ភ :

ដំឡូងឈើជាប្រភេទដំណាំមើមមួយមុខដែលកសិករខ្មែរ

យើងនិយមដាំជាងគេ ។ ក្រៅពីមើមរបស់ដំឡូងឈើនៅតាមទីជនបទខ្លះៗ គេនៅនិយមយកត្រួយស្លឹកទៅធ្វើជាបន្លែ បានយ៉ាងឆ្ងាញ់ពិសាទៀតផង។ ក្នុងស្លឹកត្រួយដំឡូងឈើក៏មាននូវវីតាមីនអាខ្លះដែរ ដែលអាចជួយការពារជំងឺភ្នែកនានារបស់កុមារតូចៗបាន ។ ក្នុងមើមដំឡូងឈើសំបូរទៅដោយជាតិម្សៅ ដែលអាចឱ្យបរិភោគជាអាហារទ្រទ្រង់រាងកាយបានយ៉ាងប្រសើរ ។ ដូច្នេះក្នុងកាលៈទេសៈខ្វះខាតស្បៀង ដំឡូងឈើមានតួនាទីសំខាន់សំរាប់ទ្រទ្រង់រាងកាយកុមារក៏ដូចជា មនុស្សយើងគ្រប់រូបដែរ ។ ដំឡូងឈើគេអាចយកទៅកែច្នៃជាបន្លែសំរាប់មុខម្ហូបផ្សេងៗ ឬ ធ្វើជាបង្អែម ។ល។ ម្យ៉ាងទៀតក្រៅពីប្រើប្រាស់ជាផលប្រយោជន៍បានច្រើន ដំឡូងឈើជាប្រភេទដំណាំមើមដែលងាយដាំនឹងថែរក្សាបំផុត ដូចនេះគ្រួសារខ្មែរយើងគួរនាំគ្នាដាំទុក សំរាប់ជាប្រយោជន៍គ្រួសារកុំបីខាន ។

Code:
Date:
Donated by: